២០១៨

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៨០ MIH / ២០១៨

ថ្ងៃ សុក្រ ១១កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៨

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណរដ្ឋប្រជាមានិតចិននៅកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពីកម្មសិទ្ធិបញ្ញា រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧
- បានឃើញប្រកាសលេខ ៤៥១ MIH/2014 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

# សម្រេច
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១._ គោលបំណង

ប្រកាសនេះ មានគោលបំណងអនុវត្តការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណរដ្ឋប្រជាមានិតចិន (ចិន) នៅកម្ពុជា ដោយអនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម និងអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពីកម្មសិទ្ធិបញ្ញា រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន។

### ប្រការ២._ គោលដៅ

ប្រកាសនេះ មានគោលដៅ ៖

- កំណត់អំពីនីតិវិធីនៃការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិន នៅកម្ពុជា
- កំណត់បែបបទនៃការរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្មចិន នៅកម្ពុជា
- កំណត់យន្តការទទួលបន្ទុកពិនិត្យ និងគ្រប់គ្រងប្រកាសនីយបត្រតក្កកម្មចិន ដែលត្រូវបានទទួលស្គាល់នៅកម្ពុជា។

### ប្រការ៣._ វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់នៅប្រទេសចិន ហើយស្នើសុំចុះបញ្ជីទទួលស្គាល់នៅកម្ពុជា។

### ប្រការ៤._ វាក្យស័ព្ទ

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានបកស្រាយដូចខាងក្រោម ៖

- **ច្បាប់ប្រកាសនីយបត្រតក្កកម្ម** សំដៅដល់ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៧/០១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។
- **ប្រកាសនីយបត្រតក្កកម្មចិនដែលត្រូវបានទទួលស្គាល់នៅកម្ពុជា** មានន័យថា ប្រកាសនីយបត្រតក្កកម្មចិន ដែលត្រូវបានផ្តល់នៅអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និងបានស្នើសុំចុះបញ្ជីទទួលស្គាល់នៅកម្ពុជា។
- **រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។
- **មន្ត្រីកាន់កាប់បញ្ជី** សំដៅដល់ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។
- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** សំដៅដល់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

## ផ្នែកទី២
## ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

### ប្រការ៥._ ការដាក់ពាក្យស្នើសុំ និងការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

ការដាក់ពាក្យស្នើសុំ និងការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវធ្វើនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

### ប្រការ៦._ ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវបំពេញតាមគំរូលិខិតយថាភូត ដែលមានភ្ជាប់ជាឧបសម្ព័ន្ធ ១(ចទប្រត.ច)ហើយអ្នកដាក់ពាក្យសុំត្រូវបំពេញឱ្យបានត្រឹមត្រូវនូវ ៖

ក. ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋានរបស់អ្នកដាក់ពាក្យសុំនីមួយៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំនីមួយៗផងដែរ។

ខ. ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ ពាក្យសុំចុះបញ្ជីត្រូវបញ្ជាក់ និងបង្ហាញពីឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារនោះ និងត្រូវមានលិខិតផ្ទេរសិទ្ធិតំណាងភ្ជាប់មកជាមួយ។

គ. ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១- ច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មចិន ដោយមានការបញ្ជាក់ថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើមពីអង្គភាពកម្មសិទ្ធិបញ្ញាវដ្ឋចិន។

២- ឯកសារចម្លងសេចក្ដីពណ៌នាលម្អិតនៃប្រកាសនីយបត្រតក្កកម្មចិន ដោយមានការបញ្ជាក់ពីអង្គភាពកម្មសិទ្ធិបញ្ញាវដ្ឋចិន ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ដែលបានផ្ដល់រួមមាន៖

-សេចក្ដីអធិប្បាយ

-សេចក្ដីអះអាង

-ខ្លឹមសារសង្ខេប

-គំនូរបង្ហាញ(ប្រសិនបើមាន)

៣- ឯកសារបកប្រែជាភាសាខ្មែរទាក់ទងទៅនឹងចំណុច គ.២.ត្រេទី១ គ.២.ត្រេទី២ គ.២.ត្រេទី៣ និង គ.២.ត្រេទី៤ នៃប្រការនេះ ត្រូវផ្ដល់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទដែលបានដាក់សំណើសុំចុះបញ្ជីទៅមន្ត្រីកាន់កាប់បញ្ជី។

ឃ. ការដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវបង់កម្រៃសេវា ស្របតាមប្រកាសរួម ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ។

### ប្រការ៧._ លក្ខខណ្ឌតម្រូវនៃការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវស្របនឹងប្រការ៨ នៃប្រកាសនេះ ហើយត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

១- ត្រូវមានសុពលភាពការពារក្នុងអំឡុងពេលនៃការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា

២- ត្រូវមានកាលបរិច្ឆេទសុំចុះបញ្ជីក្រោយថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ និងត្រូវស្របតាមមាត្រា៤ និងមាត្រា៩ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

## ប្រការ៨_ ការចុះលេខលើពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

មន្ត្រីកាន់បញ្ជីត្រូវចុះកំណត់សម្គាល់នៅលើឯកសារនីមួយៗ នៃសំណុំលិខិតស្នើសុំនូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលពាក្យសុំ និងលេខសំណុំលិខិតស្នើសុំដែលផ្តុំដោយអក្សរ "កជ" បន្ទាត់ទ្រេត "/" អក្សរ "ចទប្រត.ច" បន្ទាត់ទ្រេត "/" លេខបួនខ្ទង់នៃឆ្នាំ ដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល។

## ប្រការ៩_ ការត្រួតពិនិត្យលើពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

ការត្រួតពិនិត្យលើពាក្យស្នើសុំត្រូវអនុវត្តដូចខាងក្រោម៖

១- មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យថា តើពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវហើយឬនៅ។

២- ប្រសិនបើមានតម្រូវការចាំបាច់ណាមួយ មន្ត្រីកាន់កាប់បញ្ជីអាចអញ្ជើញអ្នកដាក់ពាក្យសុំមកផ្តល់ឯកសារកែតម្រូវទាំងអស់ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល២(ពីរ)ខែ គិតចាប់ពីថ្ងៃជូនដំណឹង។

៣- ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវហើយនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិន និងត្រូវចេញវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មចុះបញ្ជីនោះជូនអ្នកដាក់ពាក្យស្នើសុំ។

៤- លេខចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិន ត្រូវចុះកំណត់សម្គាល់ដែលផ្តុំដោយអក្សរ "កជ" បន្ទាត់ទ្រេត "/" អក្សរ "ផចទប្រត.ច" បន្ទាត់ទ្រេត "/" លេខបួនខ្ទង់នៃឆ្នាំ ដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃការចុះបញ្ជី។

## ប្រការ១០_ កាលបរិច្ឆេទទទួលពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

កាលបរិច្ឆេទទទួលពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា និងកាលបរិច្ឆេទសុំចុះបញ្ជីទទួលប្រកាសនីយបត្រតក្កកម្មចិន ត្រូវអនុវត្តដូចខាងក្រោម៖

១- កាលបរិច្ឆេទទួលពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា គឺជាកាលបរិច្ឆេទដែលបានទទួលឯកសារទាំងអស់ ដូចមាននៅក្នុងចំណុច គ.១ គ.២ នៃប្រការ៦ និងបង់កម្រៃសេវាដូចមានចែងក្នុងចំណុច **ឃ** នៃប្រការ៦ នៃប្រកាសនេះ។

២- កាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា គឺជាកាលបរិច្ឆេទដូចគ្នា និងកាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅចិន។

៣- កាលបរិច្ឆេទចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា គឺជាកាលបរិច្ឆេទចេញវិញ្ញាបនបត្រចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា។

## ប្រការ១១_ ការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

ប្រកាសនីយបត្រតក្កកម្មចិន ដែលចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវអនុវត្តដូចខាងក្រោម៖

១- ប្រកាសនីយបត្រតក្កកម្មចិន ដែលចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវអនុវត្តដូចប្រកាសនីយបត្រតក្កកម្មដែលផ្តល់ដោយមន្ត្រីកាន់កាប់បញ្ជី ហើយស្របតាមមាត្រា៣៨ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែលៈ mih.smcabinet@gmail.com

២- កាលបរិច្ឆេទនៃការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវដូចគ្នានឹងកាលបរិច្ឆេទនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មចិន ហើយត្រូវស្របតាមមាត្រា៣៨នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម។

## ប្រការ១២._ការបង់កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំ

ការបង់កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំ សម្រាប់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវអនុវត្តដូចខាងក្រោម ៖

១- ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវបង់កម្រៃសេវាដូចមានចែងក្នុងប្រកាសរួម ស្តីពីការពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២- កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មចិន ដែលបានចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវបង់ដោយរាប់បន្តពីកាលបរិច្ឆេទចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្មនោះ ដោយផ្អែកលើកាលបរិច្ឆេទសុំចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្ម។

៣- កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវបង់ក្នុងរយៈពេល ៣ (បី)ខែ ចាប់ពីកាលបរិច្ឆេទជូនដំណឹងបង់ប្រាក់។

## ប្រការ១៣._សិទ្ធិអ្នកប្រើប្រាស់មុន ទាក់ទងប្រកាសនីយបត្រតក្កកម្មចិន

សិទ្ធិអ្នកប្រើប្រាស់មុន ទាក់ទងប្រកាសនីយបត្រតក្កកម្មចិន ដែលចុះបញ្ជីនៅកម្ពុជារួមមាន៖

១- សិទ្ធិទទួលបានពីការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា មិនត្រូវអនុវត្តចំពោះសកម្មភាពដែលប្រព្រឹត្តក្នុងគោលបំណងល្អដោយបុគ្គលណាម្នាក់ ដែលប្រើប្រាស់តក្កកម្ម ឬក៏ធ្វើការរៀបចំឱ្យមានប្រសិទ្ធភាព និងហ្មត់ចត់នូវតក្កកម្មនោះ ឬធ្វើអាជីវកម្មមុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមមាត្រា៤៤(ឃ) នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម ។

២- រូបវន្តបុគ្គលដែលប្រើប្រាស់តក្កកម្មនេះក្នុងគោលបំណងល្អ ឬក៏ការរៀបចំឱ្យមានប្រសិទ្ធភាព និងហ្មត់ចត់នូវតក្កកម្មនោះ ឬធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មុនកាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិនស្ថិតក្រោមផ្នែកនេះ មានសិទ្ធិបន្តធ្វើសកម្មភាព ឬក្នុងករណីដែលអាច ឬធ្វើសកម្មភាពនោះ ទោះជាមានការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមមាត្រា៤៤(ឃ) នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម។

៣- យោងតាមប្រការ១៣នៃប្រកាសនេះ សិទ្ធិរបស់អ្នកប្រើប្រាស់មុនអាចផ្ទេរ ឬប្រគល់បានជាមួយតែសហគ្រាស ឬក្រុមហ៊ុន ឬមួយផ្នែកនៃសហគ្រាស ឬក្រុមហ៊ុនដែលបានប្រើប្រាស់ ឬបានរៀបចំការប្រើប្រាស់តក្កកម្មនោះរួចហើយ។

## ប្រការ១៤._ការបញ្ចប់សិទ្ធិ

១- ក្នុងករណីមានការបញ្ចប់សិទ្ធិប្រកាសនីយបត្រចិន ដោយសារការបង់កម្រៃមិនទាន់ពេលវេលាប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា មិនមានឥទ្ធិពលអ្វីឡើយ។

២- ការបញ្ចប់សិទ្ធិនៃប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវអនុវត្តបន្ទាប់ពីទទួលបានការជូនដំណឹងពីអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម អំពីការអស់សុពលភាពប្រកាសនីយបត្រតក្កកម្មចិនក្រោយពីនីតិវិធីដោះស្រាយតាមផ្លូវច្បាប់ត្រូវបានបញ្ចប់។

៣- ក្នុងករណីមានការផ្លាស់ប្តូរលើឯកសារប្រកាសនីយបត្រតក្កកម្ម រួមមាន៖ សេចក្តីអធិប្បាយ សេចក្តីអះអាង និងខ្លឹមសារសង្ខេប នៃប្រកាសនីយបត្រតក្កកម្មចិន អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ត្រូវជូនដំណឹងដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

៤- ក្នុងករណីមានវិវាទ ប្រសិទ្ធភាពផ្លូវច្បាប់នៃប្រកាសនីយបត្រតក្កកម្មចិន ដែលបានចុះបញ្ជីនៅកម្ពុជា ត្រូវដូចគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្មចិន ក្រោយពីនីតិវិធីដោះស្រាយតាមផ្លូវច្បាប់ត្រូវបានបញ្ចប់។

## ជំពូកទី៣
## ការដោះស្រាយទំនាស់ និងកិច្ចសហការ

### ប្រការ១៥._ ការដោះស្រាយទំនាស់

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសមត្ថកិច្ចសម្របសម្រួល និងដោះស្រាយទំនាស់ដែលពាក់ព័ន្ធនឹងការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា។ ក្នុងករណីមិនអាចដោះស្រាយបាន គូភាគីដែលពាក់ព័ន្ធអាចដោះស្រាយតាមផ្លូវតុលាការដែលមានសមត្ថកិច្ច។

### ប្រការ១៦._ កិច្ចសហការ

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវសហការជាមួយអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីជំរុញការការពារប្រកាសនីយបត្រតក្កកម្មចិនដែលត្រូវបានចុះបញ្ជីទទួលស្គាល់នៅកម្ពុជា។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

### ប្រការ១៧._ និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ១៨._ សមត្ថកិច្ចអនុវត្ត

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងនីតិបុគ្គល ឬរូបវន្តបុគ្គលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ។

### ប្រការ១៩._ ប្រសិទ្ធភាព

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u> ៖**
-ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-រដ្ឋបាលរាជធានី ខេត្ត
-ដូចប្រការ
-ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com